# សាលារៀនជំនាន់ថ្មី អនុវិទ្យាល័យ គោកព្រីង
# ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

## ត្រូវការជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តមបន្ថែម

*សម្រាប់ឆ្នាំសិក្សា២០១៧ -២០១៨*

ដោយមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ព្រមទាំងដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា ដែលបានជួយឧបត្ថម្ភទាំងធនធានបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការ ChildFund Cambodia **អនុវិទ្យាល័យ គោកព្រីង** មានការអភិវឌ្ឍយ៉ាងឆាប់រហ័សទាំងបរមាណ និងគុណភាព។

**អនុវិទ្យាល័យ គោកព្រីង** បានក្លាយជាសាលារៀនជំនាន់ថ្មីគំរូដំបូងគេនៅក្នុងទឹកដីខេត្តស្វាយរៀង ដែលមានបរិស្ថានសិក្សាទំនើប អភិបាលកិច្ចល្អ និងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនខ្ពស់ ទទួលបានការទុកចិត្ត កោតសរសើរពីមាតាបិតា សិស្សានុសិស្ស និងសហគមន៍ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ថ្មីៗនេះ អនុវិទ្យាល័យ គោកព្រីង ទទួលបានគោលការណ៍ឯកភាពពីមន្ទីរ និងអង្គការដៃគូដែលកំពុងអនុវត្តកម្មវិធី ដើម្បីជ្រើសរើសគ្រូបង្រៀនបន្ថែមបំពេញសេចក្តីត្រូវការសាលាដូចខាងក្រោម៖

១. គ្រូបង្រៀនកម្រិតឧត្តម និងមូលដ្ឋានចំនួន៦រូប៖ ឯកទេសគណិតវិទ្យា១រូប បច្ចេកវិទ្យាព័ត៌មាន១រូប រូបវិទ្យា១រូប ភាសាខ្មែរ ២រូប និង ភាសាអង់គ្លេស ១រូប

**លក្ខណៈសម្បត្តិ**

- ❖ ជាគ្រូបង្រៀនក្នុងក្របខ័ណ្ឌរដ្ឋដែលកំពុងបម្រើការក្នុងគ្រឹះស្ថានសិក្សារដ្ឋ។
- ❖ ជាគ្រូបង្រៀនទើបនឹងបញ្ចប់វគ្គបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ (គ្រូបង្រៀនកម្រិតឧត្តម) ឬបញ្ចប់វគ្គបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យភូមិភាគ (គ្រូបង្រៀនកម្រិតមូលដ្ឋាន) មានឆន្ទៈមោះមុតក្នុងការបំពេញការងារបង្រៀនស្របតាមកម្មវិធីកំណែទម្រង់វិស័យអប់រំ។

- មានចំណេះដឹងជ្រៅជ្រះលើមុខវិជ្ជាឯកទេស និងគរុកោសល្យ។
- មានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងការស្រាវជ្រាវទំនើបៗ។
- មានអាយុមិនលើស៣០ឆ្នាំ។

**ឱកាស និងអត្ថប្រយោជន៍៖**

- ទទួលបានកុំព្យូទ័រយួរដៃមួយគ្រឿងសម្រាប់បំពេញការងារប្រចាំថ្ងៃ។
- ទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បច្ចេកវិទ្យាICTក្នុងវិស័យ អប់រំ ការបំប៉នភាសាអង់គ្លេស វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីពង្រឹងគន្លងអាជីពគ្រូបង្រៀន
- ពង្រឹងសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឆ្លើយតបនឹងសមាហរណកម្មអាស៊ាន និងតម្រូវការអប់រំស្របនឹងនិន្នាការសាកលភាវូបនីយកម្មក្នុងសតវត្សទី២១
- ទទួលបានថវិកាលើកទឹកចិត្តតាមការបំពេញភារកិច្ចប្រចាំខែប្រមាណ ៤០០ ០០០ រៀល(លើកលែងវិស្សមកាល) បន្ថែមលើប្រាក់បៀវត្សរបស់រាជរដ្ឋាភិបាល និងប្រាក់ឧបត្ថម្ភផ្សេងទៀតអាស្រ័យលើទំហំការងារបន្ថែម។
- ទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមកម្មវិធីទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស។

**លក្ខខណ្ឌ:**

- គ្រូបង្រៀនដែលបានជ្រើសរើសមិនអនុញ្ញាតឲ្យរកកម្រៃពីសិស្សដូចជាការលក់ដូរនំចំណី ក្រដាសប្រឡង ឯកសារមេរៀន និងការបង្រៀនគួឯកជន
- ត្រូវបំពេញការងារបង្រៀនឲ្យបានយ៉ាងហោចណាស់គ្រប់ម៉ោងកំណត់របស់ក្រសួង។
- ទទួលការវាយតម្លៃប្រចាំឆ្នាំដោយក្រុមប្រឹក្សាភិបាលលើការបំពេញភារកិច្ច
- ក្រុមប្រឹក្សាភិបាលនឹងធ្វើការជ្រើសរើសធ្វើឡើងដោយផ្អែកលើសមត្ថភាពបេក្ខជនដែលមានចំណាប់អារម្មណ៍ សូមយកប្រវត្តិរូបសង្ខេប(CV)មកដាក់នៅទីចាត់ការ**អនុវិទ្យាល័យ គោកព្រីង** រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃ

ផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃ៣០ ខែសីហា ឆ្នាំ២០១៧ ឬទំនាក់ទំនងមក:

**១. លោក គង់ ណារិន ៖ នាយកអនុវិទ្យាល័យ គោកព្រីង**

ទូរស័ព្ទ ០៩៦ ៥៥០ ១៨១៦

**២.លោក លៀង សុវណ្ណនី ៖ ប្រធានគម្រោងសាលារៀនជំនាន់ថ្មី ខេត្តស្វាយរៀង**

លេខទូរស័ព្ទ ០៨៩ ៥៩៤ ៩៧១

Email: sovanny@kapekh.org

បញ្ជាក់៖ សូមទាញយកពាក្យស្នើរសុំបង្រៀននៅសាលារៀននេះតាមរយៈ Link ខាងក្រោម៖

https://drive.google.com/open?id=0B-04lFdHujFeNDZMQld0ek1lNjA